នាយកដ្ឋានបុគ្គលិក
លេខ 1107
ចូលថ្ងៃទី 11 ខែ 09 ឆ្នាំ 2018
ម៉ោង 9 ម៉ោង 30
បញ្ជូនទៅ ...
១៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ............ អនុក្រ.បក

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
នាយកដ្ឋានរដ្ឋបាលទូទៅ
ចូល
លេខ ...
ថ្ងៃទី ... ខែ ... ឆ្នាំ ...
ម៉ោង ...
បញ្ជូនទៅ ...

# អនុក្រឹត្យ
## ស្តីពី
## ការបញ្ចប់មុខតំណែងទីប្រឹក្សា និងជំនួយការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/............ ចុះថ្ងៃទី......៦...... ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់

### ស ម្រេ ច

**មាត្រា ១** : បញ្ចប់មុខតំណែងទីប្រឹក្សា ជំនួយការទាំងអស់របស់ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ទីប្រឹក្សា ជំនួយការទាំងអស់របស់ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី, ទីប្រឹក្សា ជំនួយការទាំងអស់របស់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, ទីប្រឹក្សា ជំនួយការអមក្រសួង-ស្ថាប័នទាំងអស់ និងទីប្រឹក្សាជំនួយការអង្គភាពចំណុះក្រសួង-ស្ថាប័នទាំងអស់ ដែលបានតែងតាំងដោយអនុក្រឹត្យ មុនថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ............ ខែ ............ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ